Government of South Australia

HomeStart FINANCE

Khmer 05/07

# **ថវិកាហូមស្តាត** (HomeStart Finance)

ការទិញផ្ទះខ្លួនឯងគឺជាការធ្វើសំរេចជោគជ័យយ៉ាងសំបើមមួយក៏ប៉ុន្តែការទទួលខ្ចីប្រាក់ទិញផ្ទះដ៏ត្រឹមត្រូវគឺជាការប្រជែងមួយ។

ហូមស្តាតបានជួយមនុស្សគ្រប់ប្រភេទ, សូមអរគុណដល់ការឲ្យខ្ចីប្រាក់ទិញផ្ទះរបស់យើងដែល អាចលៃលកធ្វើបាន។ ចាប់ពីអ្នករកទិញផ្ទះលើកដំបូងហើយនិងអ្នកដែលចង់ធ្វើឲ្យជីវិតរស់នៅ របស់គេបានប្រសើរឡើង រហូតដល់អ្នកដែលមានបំណងនឹងចង់ដកប្រាក់ពីធនធានដែលមាននៅក្នុងផ្ទះរបស់គេ, ហូមស្តាត អាចចាត់ចែងប្រាក់ឲ្យខ្ចីទិញផ្ទះយ៉ាងសមរម្យសំរាប់ស្ទើតែគ្រប់ៗគ្នា។

ទោះបីជាស្ថានភាពរបស់អ្នកយ៉ាងដូចម្តេចក៏ដោយ, ហូមស្តាតនៅជួយអ្នកដើម្បីស្វែងរកដំណោះស្រាយដ៏ល្អប្រសើរ ដូច្នេះអ្នកអាចនឹងធ្វើសំរេចតាមការសុបិន្តរបស់អ្នកដើម្បីទទួលធ្វើជាម្ចាស់ផ្ទះ។

## *ហេតុអ្វីបានជាខ្ញុំត្រូវការជ្រើសរើសយកហូមស្តាត?*

ហូមស្តាតអាចផ្តល់ជូនអ្នកនូវផលប្រយោជន៍ដូចតទៅនេះ៖

- ការសងប្រាក់វិញដែលមានរបាំងសុវត្ថិភាព –ការសងប្រាក់ជំពាក់វិញដោយគ្មានការព្រួយបារម្ភដែលមិនចងភ្ជាប់ទៅនឹងអត្រាចុងការប្រាក់ហើយជាធម្មតាវាកើនកំរិតអត្រាតែម្តងប៉ុណ្ណោះ ក្នុងមួយឆ្នាំ គឺវាអាស្រ័យលើកំរិតឡើងចុះនៃការរស់នៅជាមធ្យម។
- ឥតមានបង់ថ្លៃធានារ៉ាប់រងសំរាប់អ្នកឲ្យខ្ចីប្រាក់–លទ្ធភាពអាចឲ្យអ្នកចំណេញបានប្រាក់រាប់ពាន់ដុល្លារ
- ជ្រើសរើសបន្ថែមប្រាក់ពីលើ ចំពោះអ្នកមានប្រាក់បៀវត្តន៍ទាប ដោយទទួល ខ្ចីប្រាក់បណ្តាក់
- ការខ្ចីប្រាក់ប្រើប្រាស់ផ្ទាល់ខ្លួនអាចវាយតំលៃជូនបានតាមទូរស័ព្ទ
- ប្រាក់ឲ្យខ្ចីដែលមានលទ្ធភាពអាចដកចេញវិញបាន, ការបង់ប្រាក់ដែលអាចឡើងចុះបាន, ដែលអាចផ្លាស់ប្តូរបានយ៉ាងស្រួល, អត្រាចុងការប្រាក់ដែលអាចកំណត់និងបំបែក, ហើយនិងជ្រើសរើសចំពោះធនធានដែលមាន។

## *តើខ្ញុំមានលទ្ធភាពខ្ចីប្រាក់ហូមស្តាតឬទេ?*

ដើម្បីនឹងអាចមានលទ្ធភាពខ្ចីប្រាក់ហូមស្តាតបាន, អ្នកត្រូវតែ៖

- មានប្រាក់ចំណូលទៀងទាត់ (នេះអាចរាប់បញ្ចូលទាំងប្រាក់ចំណូលពីក្រសួង Centrelink. )
- មានអាយុលើសពី១៨ឆ្នាំ
- មានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍ឬក៏មានសញ្ជាត្តិអូស្ត្រាលី
- មានបំណងនឹងរស់នៅក្នុងផ្ទះដែលអ្នកទិញ
- ទិញផ្ទះរបស់អ្នកនៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង

## *សូមជួយឲ្យខ្ញុំបានចាប់ផ្តើម*

ដើម្បីនឹងពិភាក្សាពីសេចក្តីត្រូវការរបស់អ្នក, ឬក៏ចាប់ផ្តើមទទួលយល់ព្រមថាឲ្យខ្ចីប្រាក់ជាមុន, សូមទាក់ទងមកហូមស្តាតតាមទូរស័ព្ទលេខ (08) 8203 4000 ឬក៏ទូរស័ព្ទឥតគិតប្រាក់ តាមលេខ 1800 018 788 បើនៅខាងក្រៅតំបន់ជាយទីក្រុង។

មានកំណត់លក្ខ័ណ្ឌ, កិច្ចព្រមព្រៀងនិងលក្ខណវិនិច្ឆ័យនៃការព្រមព្រៀងឲ្យខ្ចីប្រាក់។ ត្រូវបង់ថ្លៃឈ្នួលនិងថ្លៃសំរាប់ការបំរើផ្សេងៗ។